

# ដំណាំស្ពៃក្តោប

## ១.ការរៀបចំដី

• ភ្ជួរដីជម្រៅ២តឹកទៅ៣តឹក(២០សង់ទីម៉ែត្រទៅ៣០សង់ទីម៉ែត្រ)

• ភ្ជួររាស់ដីឲ្យបានម៉ដល្អ ហើយហាលវាពី១០ទៅ១៥ថ្ងៃមុនដាំកូនស្ពៃក្តោប



### ការលើករងដាំ៖

កសិករត្រូវចាប់ផ្តើមលើករងដាំកូនស្ពៃក្តោបឲ្យរួចរាល់មុនអាយុកាលកូនត្រូវដាំ។ របៀបធ្វើរងដាំស្ពៃក្តោបមានដូចខាងក្រោម៖

- ទទឹងរង១ម៉ែត្រ
- បណ្តោយ រងធ្វើតាមលទ្ធភាពតែមិនគួរលើសពី ២៥ ម៉ែត្រទេ។ ការលើករងវែងពេកកសិករនឹងពិបាកចូលស្រោចទឹក ធ្វើស្មៅដាក់ជីបាញ់ថ្នាំ និងប្រមូលផល។
- លើករងនៅរដូវវស្សាគួរមានកំពស់ពី៣តឹកទៅ៥តឹក(៣០សង់ទីម៉ែត្រ-៥០សង់ទីម៉ែត្រ)
- ចន្លោះពីគុម្ពមួយទៅគុម្ពមួយមានប្រវែង៥០សង់ទីម៉ែត្រ
- ចន្លោះពីជួរមួយ ទៅជួរមួយមានប្រវែង៥០សង់ទីម៉ែត្រ




• ច្របល់ជីលាមកសត្វពុកផុយ ឬជីកំប៉ុស្ត ១-២ គីឡូក្រាមលាយជាមួយជី អិន ប៉េ កា(២០.២០.១៥) ចំនួន១០ក្រាម (១ស្លាបព្រាបាយ)សំរាប់ស្ពៃក្តោប១ដើម ឬ ជី ២០.២០.១៥ ចំនួន៦,៤ គីឡូក្រាមសម្រាប់ផ្ទៃដី ៥០០ម²។ ជៀសវាងដាក់ជីលាមកសត្វមិនទាន់ពុកផុយទ្រាប់បាតពីព្រោះវាបង្កឲ្យកូនស្ពៃក្តោបរលួយបន្ទាប់ពីដាំហើយ។

### ផលប្រយោជន៍នៃការដាក់ជីទ្រាប់បាត៖

• ដាក់ជីលាមកសត្វ ពុកផុយ ឬជីកំប៉ុស្តទ្រាប់បាតជួយឲ្យដីធូ ឫសងាយដុះលូតលាស់

• ដាក់ជី អិន ប៉េ កា ទ្រាប់បាតវាជំរុញកូនបន្លែទើបដាំរួចដុះឫសបានច្រើននិងរឹងមាំ ហើយដើមនិងស្លឹកលូតលាស់បានឆាប់រហ័ស។



## ២. ការធ្វើរោងបណ្តុះកូនស្ពៃក្តោប

• ត្រូវសង់រោង នៅកន្លែងណាដែលមានពន្លឺថ្ងៃគ្រប់គ្រាន់ និងមិននៅក្បែរដើមឈើ

• ធ្វើដំបូលប្លាស្ទិក ពណ៌ស ដើម្បីឲ្យពន្លឺថ្ងៃចាំងចូលកូនបន្លែ គ្រប់គ្រាន់នៅរដូវវស្សា និងរដូវប្រាំងធ្វើដំបូលពីសំណាញ់កាត់ពន្លឺ។ ជៀសវាងធ្វើដំបូលរោងកូនបន្លែពីស្លឹកដូង តង់ពណ៌ខៀវ ឬពីសម្ភារៈផ្សេងទៀត ដែលមិនអាចឲ្យពន្លឺថ្ងៃចូល និងធ្វើគ្រាប់បន្លែដុះយឺត ដើមកូនបន្លែទន់ ឬរលួយ។

• ដំបូលរោងមានកំពស់ ពី២ -២.៥ម៉ែត្រ

• រានបណ្តុះគួរមានកំពស់កន្លះម៉ែត្រពីដី

• រានបណ្តុះអាចធ្វើពីឫស្សី ក្តារ និងសម្ភារៈដទៃទៀតអាចរកបាន។ មិនត្រូវក្រាលដី បាវក្រចៅឬសម្ភារៈណាដែលជក់ទឹកនៅខាងក្រោមកន្ទោង ឬថាសបណ្តុះនោះទេ ពីព្រោះវាអាចនាំមកជាមួយនូវជំងឺ និងធ្វើឲ្យឫសចាក់ចុះហួសកន្ទោងបណ្តុះនាំឱ្យដាច់ឫស នៅពេលដកយកទៅដាំ។

• គ្របសំណាញ់សត្វល្អិតពណ៌ស



រានបណ្តុះកូនបន្លែសម្រាប់រដូវប្រាំង

## ៣. ការបណ្តុះគ្រាប់ស្ពៃក្តោប

### ការរៀបចំដីបណ្តុះគ្រាប់:

យកដីមានជីជាតិ១ ភាគលាយជាមួយជីលាមកគោស្ងួត ឬជីកំប៉ុស្ដិ៍២ភាគ និងផេះអង្កាម ពី២ ទៅ ៣ ភាគ អាស្រ័យតាមប្រភេទដី (ផេះអង្កាមត្រូវត្រាំទឹករយៈពេល ពី២ ទៅ ៣យប់) ។ យកល្បាយដែលបាន លាយច្របល់ហើយទៅលីងឬចំហុយរហូតក្តៅសព្វ តែត្រូវឲ្យដីនោះនៅសើមតិចៗទើបមិនខូចគុណភាពដី។



• ស្រោចទឹកឲ្យជោគដីបណ្តុះមុនដាក់គ្រាប់

• ដាក់គ្រាប់ស្ពៃក្តោប ១គ្រាប់ ក្នុង១ប្រហោះថាសបណ្តុះ ឬ១កន្ទោងរួចយកដីរោយលុបពីលើគ្រាប់។ មិនត្រូវកប់គ្រាប់ជ្រៅក្នុងដីបណ្តុះ នោះទេវាអាចធ្វើឲ្យគ្រាប់រលួយ ឬដុះយឺត។

## ៤ . ការដាំកូនស្ពៃក្តោប

កូនស្ពៃក្តោបមានអាយុ២២-២៥ថ្ងៃ (មានស្លឹកបី )យើងយកវាទៅដាំបាន។ បើយើងដាំវាមានអាយុចាស់ជាងនេះ យើងនឹងខាត ផលប្រយោជន៍ដូចជា៖

• កូនស្ពៃក្តោបខ្សោយ( ស្គមៗ) និងលូតលាស់